

# ខ្ញុំចូលចិត្តពណ៌

Let's Read

The Asia Foundation



ផ្លែប៉េងប៉ោះ និងផ្លែទទឹម មានពណ៌ក្រហម។
ខ្ញុំចូលចិត្តញ៉ាំផ្លែប៉េងប៉ោះ និងផ្លែទទឹម។



ផ្លែស្វាយទុំ និងផ្លែចេកមានពណ៌លឿង។

ខ្ញុំចូលចិត្តញ៉ាំផ្លែស្វាយទុំ និងផ្លែចេក។



ផ្លែក្រូចឃ្វិច និងមើមការ៉ុតមានពណ៌ទឹកក្រូច។
ខ្ញុំចូលចិត្តញ៉ាំផ្លែក្រូចឃ្វិច និងមើមការ៉ុត។



សណ្ដែកកួរ មានពណ៌បៃតង។
ខ្ញុំចូលចិត្តញ៉ាំសណ្ដែកកួរ ដាក់នៅក្នុងសម្លរការី។



ស្ពៃក្តោប និងឆៃថាវ មានពណ៌ស។
ខ្ញុំចូលចិត្តញ៉ាំស្ពៃក្តោប និងឆៃថាវ ដាក់នៅក្នុងសម្លរចាប់ឆាយ។



ផ្លែត្រប់មានពណ៌ស្វាយ។
ខ្ញុំចូលចិត្តញ៉ាំឆាត្រប់។



ផ្កាឈូកមានពណ៌ផ្កាឈូក។

ខ្ញុំចូលចិត្តដាក់ផ្កាឈូកថ្វាយព្រះ។



ទឹកសមុទ្រមានពណ៌ខៀវ។
ខ្ញុំចូលចិត្តមើលទឹកសមុទ្រ។



ខ្ញុំចូលចិត្តពណ៌នៅលើទង់ជាតិប្រទេសកម្ពុជា។
ទង់ជាតិប្រទេសកម្ពុជាមានបីពណ៌។



ខ្ញុំចូលចិត្តពណ៌ឥន្ទធនូ។
ឥន្ទធនូមានប្រាំពីរពណ៌។



ខ្ញុំចូលចិត្តប៉េាងប៉េាង។ ប៉េាងប៉េាងទាំងនេះមានប្រាំបីពណ៌។



ពេលយប់ មានពណ៌ខ្មៅ។
តើមានអ្វីផ្សេងទៀតដែលមានពណ៌ខ្មៅ?



**សំណួរ**

១. តើផ្លែឈើអ្វីដែលមានពណ៌លឿង?

២. តើតួអង្គនៅក្នុងរឿងនេះចូលចិត្តយកផ្កាឈូកទៅធ្វើអ្វី?

៣. តើមានអ្វីខ្លះទៀតដែលមានពណ៌ខ្មៅ?

៤. តើកូនចូលចិត្តពណ៌អ្វី?

## Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*ខ្ញុំចូលចិត្តពណ៌ (I Like Colors)*, Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/
Contributing translators: Chheang Chansomey